# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន

## កិច្ចប្រជុំលើកទី 22 • ថ្ងៃទី 30 ខែតុលា ឆ្នាំ 2025 • ម៉ោង 6:30

### កិច្ចដំណើរការប្រជុំ

- **ការបកប្រែភាសាកំពុងត្រូវបានផ្តល់ជូនជាភាសា៖ Español, Kreyòl ayisyen, 普通话, Português, Kriolu, Tiếng Việt, and American Sign Language (ASL)**
  - ដើម្បីចូលរួមជាភាសាអង់គ្លេស សូមចុចរូបតំណាង "ការបកប្រែផ្ទាល់មាត់" ហើយជ្រើសរើសភាសាអង់គ្លេស។
  - Para entrar no canal em português, clique no ícone “Interpretation” e selecione “Portuguese”
  - Si alguien desea interpretación en español, haga clic en “Interpretation” y seleccione “Spanish”
  - Pa partisipa na Kriolu, klika na íkone "Intirpretason" y silisiona "Cape Verdean Creole"
  - Pou rantre nan chanèl kreyòl ayisyen an, klike sou ikòn “Interpretation” an epi chwazi “Haitian Creole”
  - 要以普通话参加会议，请单击口语图标并选择 "Chinese”.
  - Để vào kênh bằng tiếng Việt, hãy nhấp vào biểu tượng “Interpretation” và chọn “Vietnamese”.

- សូមនិយាយយឺតៗ។
- អ្នកចូលរួមទាំងអស់ត្រូវតែជ្រើសរើសបណ្តាញភាសា ទោះបីជាការមើលបទបង្ហាញនោះជាភាសាអង់គ្លេសក៏ដោយ។



- ប្រសិនបើអ្នកចង់បានស្លាយជាទម្រង់ឯកសារបកប្រែ សូមចូលទៅកាន់គេហទំព័រ EJC តាមរយៈ: [https://www.mass.gov/service-details/environmental-justice-council-ejc-meetings](https://www.mass.gov/service-details/environmental-justice-council-ejc-meetings)

កិច្ចប្រជុំនេះកំពុងត្រូវបានថតទុក

# ក្រុមប្រឹក្សា យុត្តិធម៌បរិស្ថាន

កិច្ចប្រជុំលើកទី 22

ថ្ងៃព្រហស្បតិ៍ ទី 30 ខែតុលា ឆ្នាំ 2025 ម៉ោង 6:30 ល្ងាច

ទីតាំងផ្ទាល់៖ Leominster, MA

Leominster City Hall Auditorium

*25 West St, Leominster, MA*

# កិច្ចដំណើរការប្រជុំ និងរបៀបវារៈ

# កិច្ចដំណើរការប្រជុំ

- **ការបកប្រែភាសាកំពុងត្រូវបានផ្តល់ជូនជាភាសា៖ Español, Kreyòl ayisyen, 普通话 , Português, Tiếng Việt, and American Sign Language (ASL)**
  - ដើម្បីចូលរួមជាភាសាអង់គ្លេស សូមចុចរូបតំណាង "ការបកប្រែផ្ទាល់មាត់" ហើយជ្រើសរើស ភាសាអង់គ្លេស។
  - Para entrar no canal em português, clique no ícone “Interpretation” e selecione “Portuguese”
  - Si alguien desea interpretación en español, haga clic en “Interpretation” y seleccione “Spanish”
  - Pa partisipa na Kriolu, klika na íkone "Intirpretason" y silisiona "Cape Verdean Creole“
  - Pou rantre nan chanèl kreyòl ayisyen an, klike sou ikòn “Interpretation” an epi chwazi “Haitian Creole”
  - 要以普通话参加会议，请单击口语图标并选择 "Chinese”.
  - Để vào kênh bằng tiếng Việt, hãy nhấp vào biểu tượng “Interpretation” và chọn “Vietnamese”.
- **សូមនិយាយយឺតៗ**

- **អ្នកចូលរួមទាំងអស់ត្រូវតែជ្រើសរើសបណ្តាញភាសា ទោះបីជាការមើលបទបង្ហាញនោះជាភាសាអង់គ្លេសក៏ដោយ។**



- **ដើម្បីទទួលបានស្លាយជាទម្រង់ឯកសារបកប្រែ សូមចូលទៅកាន់គេហទំព័រ EJC តាមរយៈ៖ https://www.mass.gov/service-details/environmental-justice-council-ejc-meetings**
- **ខ្សែបណ្តាញទាំងអស់នឹងត្រូវបានបិទសំឡេងនៅអំឡុងពេលធ្វើបទបង្ហាញ។**
- **ខ្សែបណ្តាញនោះនឹងបើកដំណើរការសម្រាប់ការផ្តល់មតិផ្ទាល់មាត់ក្រោយពេលធ្វើបទបង្ហាញ។**
- **ប្រសិនបើអ្នកមានចម្ងល់ចង់សួរបញ្ហាក់ ឬបញ្ហាកិច្ចដំណើរការប្រជុំ ឬបញ្ហាបច្ចេកទេស នៅអំឡុងពេលធ្វើបទបង្ហាញ សូមវាយបញ្ចូលសំណួរនោះទៅក្នុងប្រអប់សំណួរចម្លើយ (Q&A)។**



- **សូមទាក់ទងទៅកាន់អ្នកដឹកនាំសិក្ខាសាលាអនឡាញ ERG គឺអ្នកស្រី Kecil John តាមរយៈ: meetings@erg.com បើសិនជាមានបញ្ហាបច្ចេកទេស ឬសំណួរនានា។**

កិច្ចប្រជុំនេះកំពុងត្រូវបានថតទុក

# របៀបវារៈ

| |
|---|
| ▪ ទិដ្ឋភាពទូទៅនៃកិច្ចប្រជុំ កិច្ចដំណើរការប្រជុំ និងរបៀបវារៈ |
| ▪ ការហៅឈ្មោះសមាជិក និងការអនុម័តលើកំណត់ហេតុប្រជុំ EJC ពីមុន |
| ▪ សំណួរ និងមតិយោបល់ពីសាធារណជន |
| ▪ MassEnviroScreen |
| ▪ ការធ្វើបច្ចុប្បន្នភាពគម្រោង MassSave |
| ▪ សំណួរ និងមតិយោបល់ពីសាធារណជន |
| ▪ ឆ្លើយតបចំពោះមតិយោបល់ (ប្រសិនបើសមស្រប) |
| ▪ ជំហានបន្ទាប់ និងការលើកវារកាល |



# ការអនុម័តថ្ងៃទី 12 ខែមិថុនា ឆ្នាំ 2025 កំណត់ហេតុកិច្ចប្រជុំ និងការហៅឈ្មោះសមាជិក៖ សមាជិកក្រុមប្រឹក្សា EJ

- Kalila Barnett
- Madeline Fraser Cook
- Melissa Harding-Ferretti
- Cheryll Holley
- Caroline Hon
- Lydia Lowe
- Marcos Luna
- Peter Maathey
- María Belén Power
- Sofia Owen
- Jen Salinetti
- Patricia Spence
- Ari Zorn
- Miles Gresham

# សំណួរ និងមតិយោបល់សាធារណៈ

*សូមកំណត់មតិយោបល់នីមួយៗត្រឹមរយៈពេលពីរនាទី ដើម្បីទុកពេលឱ្យអ្នកដទៃទៀតបញ្ចេញមតិ*

# MassEnviroScreen

Commonwealth of Massachusetts

Executive Office of Energy and Environmental Affairs

# លក្ខណៈទូទៅរបស់ MassEnviroScreen (កំណែព្រាង)

ការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន

ថ្ងៃទី 30 ខែតុលា ឆ្នាំ 2025



# តើ MassEnviroScreen គឺជាអ្វី?

- MassEnviroScreen គឺជាឧបករណ៍ធ្វើផែនទីដែលផ្តល់ពិន្ទុបន្ទុកបញ្ហាសរុបរួមដល់ក្រុមប្លុកជំរឿននីមួយៗនៅក្នុងរដ្ឋ Massachusetts
- ឧបករណ៍គូសផែនទីប្រើការរួមបញ្ចូលគ្នានៃព័ត៌មានបរិស្ថាន សុខភាព អាកាសធាតុ និងសេដ្ឋកិច្ចសង្គម ដើម្បីកំណត់ថាតើសហគមន៍ណាដែលរងផលប៉ះពាល់ខ្លាំងបំផុតពីការបំពុល និងងាយរងគ្រោះបំផុតពីផលប៉ះពាល់របស់វា។
- ឧបករណ៍ត្រូវបានរចនាដើម្បី៖
  - តម្លាភាព
  - សមធម៌
  - សហការ



# បរិបទគោលនយោបាយ៖ ច្បាប់ស្ដីពីអាកាសធាតុឆ្នាំ 2024

*ច្បាប់ស្ដីអំពីការលើកកម្ពស់បណ្ដាញថាមពលស្អាត ការលើកកម្ពស់សមភាព និងការការពារអ្នកបង់ថ្លៃថាមពលប្រើប្រាស់*

- ការបង្កើតការិយាល័យយុត្តិធម៌ និងសមធម៌បរិស្ថានជាផ្លូវការក្នុងលក្ខន្តិកៈ ដើម្បីអនុវត្តគោលការណ៍យុត្តិធម៌បរិស្ថាន ដូចមានកំណត់ក្នុងផ្នែកទី 62 នៃជំពូកទី 30 ក្នុងប្រតិបត្តិការរបស់ការិយាល័យ និងទីភ្នាក់ងារនីមួយៗក្រោមការិយាល័យប្រតិបត្តិ
- OEJE ក៏ទទួលខុសត្រូវក្នុងការបង្កើតគោលការណ៍ណែនាំទាក់ទងនឹងកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ និងការវិភាគផលប៉ះពាល់សរុបរួម
- ក្រុមប្រឹក្សាភិបាលទទួលបន្ទុកការប្រើប្រាស់ថាមពលនៅតាមគ្រឿងបរិក្ខារ (EFSB) ត្រូវតែប្រកាសបទប្បញ្ញត្តិសម្រាប់ការវិភាគផលប៉ះពាល់សរុបរួម ដែលជាផ្នែកមួយនៃការពិនិត្យឡើងវិញនូវគ្រឿងបរិក្ខារ បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត និងគ្រឿងបរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច។
- **MassEnviroScreen** នឹងជាឧបករណ៍ទិន្នន័យមូលដ្ឋានដើម្បីគាំទ្រការងារនេះ

# មូលហេតុដែលយើងវាស់វែងផលប៉ះពាល់រួម

*សម្រាប់គោលបំណងការពិភាក្សានេះ ផលប៉ះពាល់សរុបរួម និងបន្ទុកបញ្ហាសរុបរួមត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក។*

- **ផលប៉ះពាល់ជារួម**សំដៅលើបរិមាណផលប៉ះពាល់ពីផលបូករបស់កត្តាគីមីនិងកត្តាមិនមែនគីមីសរុប និងឥទ្ធិពលរបស់វាទៅលើសុខភាព និងលទ្ធផលគុណភាពជីវិត ។
- សហគមន៍នៅទូទាំងរដ្ឋ Massachusetts ជួបប្រទះកម្រិតផ្សេងៗគ្នានៃភាពតានតឹងផ្នែកបរិស្ថាន។
- តំបន់ជាច្រើនប្រឈមមុខនឹងបន្ទុកបញ្ហាជាច្រើនពីលើគ្នា ដូចជាការបំពុល ទឹកជំនន់ និងធនធានដែលមានកម្រិត។
- MassEnviroScreen ផ្តល់នូវឧបករណ៍ដែលអាចចូលប្រើបានជាសាធារណៈតែមួយគត់ដែលបង្ហាញពីកន្លែងដែលមានបន្ទុកបញ្ហាសរុបរួមច្រើនទាំងនេះ

# របៀបដែលឧបករណ៍ត្រូវបានអភិវឌ្ឍឡើង

- ការអភិវឌ្ឍគឺជាការងារសហការដែលដឹកនាំដោយ OEJE ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយៈ
  - ទីភ្នាក់ងាររដ្ឋ និងក្រុមការងារ GIS
  - អ្នកជំនាញផ្នែកអប់រំ និងសុខភាពសាធារណៈ
  - អង្គការតាមសហគមន៍ និងអ្នកតស៊ូមតិផ្នែកយុត្តិធម៌ផ្នែកបរិស្ថាន
  - រដ្ឋាភិបាលកុលសម្ព័ន្ធ និងអ្នកតំណាងជនជាតិដើមភាគតិច

- ដំណើរការនេះមានលក្ខណៈទូលំទូលាយនិងសហការគ្នា ដែលបង្ហាញដោយទិន្នន័យ និងបទពិសោធផ្ទាល់។

- គោលដៅគឺជាឧបករណ៍ដែលឆ្លុះបញ្ចាំងពីលក្ខណៈចម្រុះនៃសហគមន៍ក្នុងរដ្ឋ Massachusetts។

- ឧបករណ៍នេះបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលសេចក្តីព្រាង – OEJE កំពុងស្ថិតក្នុងដំណើរការកែលម្អសូចនាករ លទ្ធផលតេស្ត និងការប្រមូលមតិយោបល់ពីសាធារណជន។

# សមាសធាតុរបស់ MassEnviroScreen

***ឧបករណ៍នេះត្រូវបានផ្អែកលើកម្មវិធី CalEnviroScreen របស់រដ្ឋ California – ដែលបានកែលម្អសម្រាប់រដ្ឋ Massachusetts ។***

- សូចនាកររបស់ MassEnviroScreen មានសមាសភាគចម្បងចំនួនប្រាំ - ការប៉ះពាល់ពីបរិស្ថាន ផលប៉ះពាល់ដល់បរិស្ថាន ហានិភ័យពីអាកាសធាតុ ប្រជាជនងាយរងគ្រោះ និងកត្តាសេដ្ឋកិច្ចសង្គម។
  - សូចនាករ**ការប៉ះពាល់ពីបរិស្ថាន** គឺផ្អែកលើការវាស់វែងប្រភេទការបំពុលផ្សេងៗដែលមនុស្សអាចប៉ះពាល់។
  - សូចនាករ**ផលប៉ះពាល់ដល់បរិស្ថាន** គឺផ្អែកលើទីតាំងសារធាតុគីមីពុលនៅក្នុង ឬក្បែរសហគមន៍។
  - សូចនាករ**ហានិភ័យពីអាកាសធាតុ**គឺផ្អែកលើការប៉ះពាល់ពីគ្រោះបណ្ដាលមកពីអាកាសធាតុ។
  - សូចនាករចំនួន**ប្រជាជនងាយរងគ្រោះ** វែងចំនួនមនុស្សនៅក្នុងសហគមន៍ដែលអាចរងផលប៉ះពាល់ធ្ងន់ធ្ងរជាងប្រជាជនផ្សេងទៀត ពីការបំពុលឬគ្រោះបណ្ដាលមកពីអាកាសធាតុដោយសារតែសុខភាពរបស់ពួកគេ។
  - សូចនាករ**កត្តាសេដ្ឋកិច្ចសង្គម** គឺជាស្ថានភាពដែលអាចបង្កើនភាពតានតឹងដល់មនុស្ស ឬធ្វើឱ្យការរស់នៅដោយសុខភាពល្អមានការពិបាក និងធ្វើឱ្យពួកគេងាយរកគ្រោះជាងមុនពីផលប៉ះពាល់ពីការបំពុល។

# សេចក្តីព្រាងនៃសូចនាករ MassEnviroScreen



# វិធីសាស្ត្រគំរូ

- គំរូ៖
  - ប្រើលំដាប់ភាគរយ (0 – 100) ដើម្បីកំណត់ពិន្ទុសម្រាប់សូចនាករនីមួយៗនៅក្នុងក្រុមប្លុកជំរឿនដែលបានផ្ដល់ឱ្យ។
  - ប្រើប្រព័ន្ធពិន្ទុដែលលំដាប់ភាគរយត្រូវបានជាមធ្យមសម្រាប់សំណុំសូចនាករនៅក្នុងសមាសធាតុទាំងប្រាំនីមួយៗ។
  - សូចនាករត្រូវបានរួមបញ្ចូលគ្នានៅក្នុងវិធានការផ្សំពីរ៖
    - បន្ទុកបញ្ហាការបំពុល និងអាកាសធាតុ= ការប៉ះពាល់ពីបរិស្ថាន + ផលប៉ះពាល់ដល់បរិស្ថាន + ហានិភ័យពីអាកាសធាតុ
    - លក្ខណៈប្រជាជន = ប្រជាជនងាយរងគ្រោះ + កត្តាសេដ្ឋកិច្ចសង្គម
  - បន្ទាប់ពីសមាសភាគត្រូវបានដាក់ពិន្ទុក្នុងបន្ទុកបញ្ហាការបំពុល និងអាកាសធាតុ ឬលក្ខណៈប្រជាជន ពិន្ទុត្រូវបានបញ្ចូលគ្នាដូចខាងក្រោម ដើម្បីគណនាពិន្ទុ MassEnviroScreen ទាំងមូល៖



# ការកំណត់តំបន់ដែលមានបន្ទុកបញ្ហា

- ***តំបន់ដែលមានបន្ទុកបញ្ហា***គឺជាសហគមន៍ដែលភាពតានតឹងផ្នែកបរិស្ថានកម្រិតខ្ពស់រួមនឹងភាពងាយរងគ្រោះផ្នែកសង្គមកម្រិតខ្ពស់
- សហគមន៍ត្រូវបានកំណត់ជា ***តំបន់ដែលមានបន្ទុកបញ្ហា*** នៅពេលដែលពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យមួយឬទាំងពីរខាងក្រោម៖
    - ពិន្ទុភាគរយបន្ទុកបញ្ហាសរុបរួម (ឧ. MassEnviroScore) គឺ 75 ឬខ្ពស់ជាងនេះ ឬ
    - ប្រាក់ចំណូលគ្រួសារជាមធ្យមប្រចាំឆ្នាំគឺ 65 ភាគរយ ឬតិចជាងប្រាក់ចំណូលគ្រួសារជាមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ
- ការគូសបញ្ជាក់តំបន់ដែលមានបន្ទុកបញ្ហាជួយណែនាំការវិភាគ ការធ្វើផែនការ និងការចូលរួមបន្ថែមទៀត

# MassEnviroScreen៖ ផែនទីតំបន់ដែលមានបន្ទុកបញ្ហា




34.5% នៃក្រុមប្លុកជំរឿននៅក្នុងរដ្ឋបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ដែលមានបន្ទុកបញ្ហា។

# របៀបដែល MassEnviroScreen គាំទ្រ CIA – និងលើសពីនេះ

- **MassEnviroScreen ត្រូវបានរចនាឡើងដើម្បី៖**
  - គាំទ្រដល់មូលដ្ឋានគ្រឹះសម្រាប់ការវិភាគផលប៉ះពាល់សរុបរួម (CIA) ដោយកំណត់តំបន់ដែលប្រឈមនឹងបន្ទុកបញ្ហាបរិស្ថាន សុខភាព និងសេដ្ឋកិច្ចសង្គមច្រើន។
  - កែលម្អតម្លាភាពដោយបង្ហាញពីរបៀបដែលភាពតានតឹងផ្នែកបរិស្ថាន និងសង្គមត្រួតលើគ្នានៅទូទាំងសហគមន៍។
  - បង្ហាញតំបន់ដែលមានបន្ទុកបញ្ហា ដើម្បីធ្វើការពិនិត្យឡើងវិញកាន់តែស៊ីជម្រៅក្នុងអំឡុងពេលកំណត់ទីតាំង និងដំណើរការអនុញ្ញាតសំណង់។
  - ជូនដំណឹងអំពីយុត្តិធម៌ផ្នែកបរិស្ថាន និងការពិភាក្សាអំពីសមធម៌កាន់តែទូលំទូលាយនៅទូទាំងទីភ្នាក់ងារ និងកម្មវិធី។
- **ឧបករណ៍<u>មិន</u>៖**
  - កំណត់ការសម្រេចចិត្តអនុញ្ញាតការសាងសង់ – វាគឺជាឧបករណ៍ត្រួតពិនិត្យ មិនមែនជាប្រព័ន្ធដាក់ពិន្ទុសម្រាប់ការអនុម័តការសាងសង់នោះទេ។
  - មិនជំនួសឱ្យរបាយការណ៍ CIA ដែលតម្រូវឱ្យមានទីតាំងជាក់លាក់ ទិន្នន័យកម្រិតគម្រោង។
  - កំណត់តំបន់ទាំងអស់ដែលរងផលប៉ះពាល់ដោយភាពអយុត្តិធម៌បរិស្ថាន ឬហានិភ័យបរិស្ថានជាក់លាក់
- **សម្លឹងមើលទៅមុខ៖**
  - ការរចនាឧបករណ៍មានភាពបត់បែន - នៅពេលយើងកែលម្អវា យើងស្វែងយល់ពីរបៀបដែលវាអាច

# របៀបដែលអ្នកអាចចូលរួម និងជំហានបន្ទាប់

- **ចូលរួមជាមួយឧបករណ៍ និងផ្តល់មតិកែលម្អ**
  - ចូលរួមក្នុងកិច្ចប្រជុំសាធារណៈ និងវគ្គផ្តល់មតិកែលម្អ
  - ពិនិត្យនិងផ្តល់មតិយោបល់ជាលាយលក្ខណ៍អក្សរលើកម្មវិធីក្នុងបណ្តាញ និងសូចនាករ
  - ចែករំលែកចំណេះដឹងក្នុងតំបន់៖ ទិន្នន័យមិនមានគ្រប់គ្រាន់ បទពិសោធផ្ទាល់ ឬអាទិភាព
  - មតិកែលម្អរបស់អ្នកជួយធ្វើឱ្យឧបករណ៍មានភាពត្រឹមត្រូវ សមធម៌ និងអាចធ្វើសកម្មភាពបាន

- **ជំហានបន្ទាប់ក្នុងការកែលម្អ MassEnviroScreen៖**
  - បន្តកែលម្អទិន្នន័យ និងសូចនាករ
  - កែលម្អលក្ខណៈការផ្ទៃផែនទី លទ្ធភាពប្រើប្រាស់ និងការមើលឃើញ
  - រួមបញ្ចូលមតិយោបល់ពីសាធារណៈទៅក្នុងកំណែចុងក្រោយ
  - បញ្ចេញឧបករណ៍ចុងក្រោយជាមួយនឹងឯកសារពេញលេញ

# សូមអរគុណ

ព័ត៌មានស្តីពីបទប្បញ្ញត្តិ ដំណើរការ និងឱកាសនៃការចូលរួមជាសាធារណៈអាចរកបាននៅលើគេហទំព័រ៖ www.mass.gov/energypermitting។ អ្នកអាចបញ្ជូនសំណួរទៅអាសយដ្ឋាន ej.inquiries@mass.gov។

# គម្រោង Mass Save - ផ្តោតលើគំនិតផ្តួចផ្តើមសមធម៌

## ថ្ងៃទី 30 ខែតុលា ឆ្នាំ 2025

Elizabeth Mahony
ស្នងការ

# កម្រោង Mass Save និងផ្តោតលើសមធម៌

សេចក្តីផ្តើម

សាវតារ - រចនាសម្ព័ន្ធផែនការមូលដ្ឋាន

ការវិភាគស៊ីជម្រៅលើវិស័យ និងដំណើររបស់អតិថិជន

ការរំលេចគំនិតផ្តួចផ្តើមថ្មីក្នុងផែនការបីឆ្នាំ 2025-2027

ឧបសម្ព័ន្ធ

# របនាសម្ព័ន្ធផែនការមូលដ្ឋាន

- ការប្រមូលផ្តុំ
- បរិវិស័យ
- កម្មវិធីជាច្រើន
- គំនិតផ្តួចផ្តើម និងវិធានការជាច្រើន

# វិស័យលំនៅឋាន

**សិទ្ធិទទួលបាន៖**

ប្រាក់ចំណូលមធ្យម (61-80% AMI/SMI)

អត្រាទីផ្សារ (> 80% AMI/SMI)

**វិធីសាស្រ្តនៃកម្មវិធី៖**

ជាកញ្ចប់- រួមបញ្ចូលវិធានការ និងគំនិតផ្ដួចផ្ដើមដែលមានការកំណត់តម្លៃថេរ និង/ឬអ្នកម៉ៅការដែលបានបញ្ជាក់

ការបង្វិលសង- រួមបញ្ចូលទាំងការផ្ដល់ជូនការបង្វិលសងទាំងអស់ និងម៉ូឌ័របូមកម្ដៅដែលកំណត់ជាមុនតាមរយៈ HPIN

ផ្ទះថ្មី និងការជួសជុលកែកុនសំខាន់ៗ- គាំទ្រតែសំណង់ថ្មីអគ្គិសនីទាំងអស់ ការបង្វិលសងដែលផ្ដល់ជូនសម្រាប់ផ្ទះដែលប្រើឧស្ម័នស្រាប់ក្នុងស្ថានភាពមានកម្រិតសម្រាប់ការជួសជុលកែកុនសំខាន់ៗ

កម្មវិធី Connected Solutions - រួមបញ្ចូលកម្មវិធីឆ្លើយតបតម្រូវការទាំងអស់

# វិស័យលំនៅឋាន

## បណ្តាញចែកចាយ

### បណ្តាញជាងដំឡើងម៉ូទ័របូមកម្តៅ

- បណ្តាញអ្នកម៉ៅការដែលទទួលបានការគាំទ្រ និងការបណ្តុះបណ្តាល (រួមទាំងអ្នកលក់ប្រេង និងប្រូប៉ានដែលបានជ្រើសរើស)។
- រួមបញ្ចូលបណ្តាញ "អ្នកដឹកនាំ" ដើម្បីបែកចែកអ្នកម៉ៅការមានគុណភាពដែលផ្តល់សេវាកម្មល្អឥតខ្ចោះ។
- មូលដ្ឋានទិន្នន័យដែលអាចស្វែងរកបានតាមអនឡាញរបស់ HPIN ដែលមានជាងដំឡើងជាង 1800 នាក់
- អតិថិជនអាចចូលរួមដោយផ្ទាល់ជាមួយអ្នកម៉ៅការ HPIN ដំឡើងម៉ូទ័របូមកម្តៅដែលមានសិទ្ធិ និងទទួលបានប្រាក់បង្វិលសងតាមរយៈអ្នកម៉ៅការ ឬដោយផ្ទាល់ជាមួយគម្រោង Mass Save

### អ្នកម៉ៅការវាយតម្លៃថាមពលក្នុងផ្ទះ

- អ្នកម៉ៅការឯករាជ្យដែលអាចផ្តល់សេវាកម្មទាំងអស់រួមទាំងការវាយតម្លៃថាមពលក្នុងផ្ទះ ការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ និងម៉ូទ័របូមកម្តៅ។
- ធ្វើទីផ្សារដោយផ្ទាល់ដើម្បីជំរុញឲ្យមានការចូលរួមពី និងទទួលបានអតិថិជន
- 24 HPCs កំពុងដំណើរការបច្ចុប្បន្ន

### អ្នកជំនាញលក់

- ផ្តល់ការវាយតម្លៃថាមពលក្នុងផ្ទះ
- ត្រួតពិនិត្យអ្នកម៉ៅការអ៊ីសូឡង់ឯករាជ្យ (83 IICs ជាមួយនឹងកិច្ចព្រមព្រៀងចូលរួម)
- ផ្តល់សេវាកម្មជាកញ្ចប់
- អនុវត្តការត្រួតពិនិត្យ QA/QC
- រក្សាជនធានរយៈពេលវែងសម្រាប់អតិថិជន

### ការបង្វិលសងសម្រាប់ការទិញតាមប្រៃសណីយ៍

- ដំណើរការបង្វិលសងប្រាក់វិញជូនអតិថិជនដែលទិញតាមប្រៃសណីយ៍
- ការបង្វិលសងប្រាក់លើផលិតផលដែលមានសិទ្ធិតាមអនឡាញ ឬទីតាំងទិញក្នុងហាង
- ការបង្វិលសងត្រូវបានដំណើរការតាមរយៈអ្នកលក់

# ដំណើររបស់អតិថិជនលំនៅឋាន

## ប្រាក់ចំណូលមធ្យម - ជាកញ្ចប់

**ជំហានទី 1** — **អតិថិជនចូលរួមកម្មវិធីពេញមួយឆ្នាំតាមវិធីផ្សេងៗគ្នា**

- សូមទាក់ទងគម្រោង Mass Save ដោយផ្ទាល់ (ការនិយាយតៗគ្នា ការធ្វើទីផ្សារ ការស្វែងរកតាមគេហទំព័រ—MassSave.com)
- ការណែនាំពីកម្មវិធី Community First Partnership (CFP)
- អ្នកម៉ៅការវាយតម្លៃថាមពលក្នុងផ្ទះ

**ជំហានទី 2** — **ការវាយតម្លៃថាមពលក្នុងផ្ទះត្រូវបានធ្វើឡើង**

**ជំហានទី 3** — **ការមានសិទ្ធិទទួលបានប្រាក់ចំណូលត្រូវបានផ្ទៀងផ្ទាត់**

**ជំហានទី 4** — **អ្នកជំនាញលក់បម្រើការជាអ្នកម៉ៅការទូទៅ៖ ការដេញថ្លៃការងារ ការគ្រប់គ្រងការចំណាយ និងការផ្តល់នូវអ្នកទំនាក់ទំនងតែមួយគត់សម្រាប់អតិថិជន**

- ការដោះស្រាយជំនះឧបសគ្គមុននឹងធ្វើការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ និងការដំឡើងប្រព័ន្ធអគ្គសនីតាមការចាំបាច់
- ការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ (ការបិទរន្ធខ្យល់ និងអ៊ីសូឡង់)
- ការដំឡើងម៉ូទ័របូមកម្តៅ
- ម៉ាស៊ីនទឹកក្តៅប្រើម៉ូទ័របូមកម្តៅក្នុងស្ថានភាពដែលបានកំណត់ជាមុន

**ជំហានទី 5** — **ការត្រួតពិនិត្យការធានាគុណភាពក្រោយការដំឡើង**

**ជំហានទី 6** — **អតិថិជនរីករាយ!**

# វិស័យដែលមានសិទ្ធិទទួលបានប្រាក់ចំណូល

**សិទ្ធិទទួលបាន៖**
< 60% SMI

**លក្ខខណ្ឌតម្រូវថវិកាបច្ចុប្បន្នតាមច្បាប់កំណត់៖** យ៉ាងហោចណាស់ 10% នៃថវិកាអគ្គិសនី និង 20% នៃថវិកាឧស្ម័ន

**វិធីសាស្ត្រនៃកម្មវិធី៖**
ផ្ទះសម្រាប់មួយគ្រួសារ (1-4 យូនីត)
ផ្ទះសម្រាប់ច្រើនគ្រួសារ (5+)
ការកែកុនផ្ទះសម្រាប់ច្រើនគ្រួសារដើម្បីសន្សំថាមពល



# វិស័យដែលមានសិទ្ធិទទួលបានប្រាក់ចំណូល

## បណ្ដាញចែកចាយ

### វិធីសាស្ត្ររបស់អ្នកជំនាញលក់ និងទីភ្នាក់ងារសកម្មភាពសហគមន៍

- លក្ខខណ្ឌតម្រូវតាមច្បាប់កំណត់សម្រាប់ CAPs អនុវត្តកម្មវិធី IE
- 23 ទីភ្នាក់ងារទូទាំងរដ្ឋ
- LEAN បម្រើការជាអ្នកគ្រប់គ្រងសម្រាប់ CAPs ទាំងអស់៖
  - សម្របសម្រួលតាងនាមឲ្យ CAPs ជាមួយ PAs និង HLC
  - គ្រប់គ្រងមជ្ឈមណ្ឌលសេវាកម្មអតិថិជន
    ទូទាំងរដ្ឋ IE
  - គ្រប់គ្រងកម្មវិធី IE Multi-Family
- អតិថិជនចូលរួមដោយផ្ទាល់ជាមួយ CAPs ឬ CAPs ផ្សព្វផ្សាយទៅកាន់អតិថិជនទទួលបានអត្រាបង្វិលសងដែលកំណត់

- PA នីមួយៗមានអ្នកជំនាញលក់ ដែលជា CAP ផងដែរ ឧ. ABCD គឺជា LV សម្រាប់ Eversource
- មានអ្នកម៉ៅការដែលបានកំណត់ធ្វើការជាមួយ LV/CAP នីមួយៗ ដើម្បីធ្វើការងារយ៉ាងមានប្រសិទ្ធភាពសម្រាប់អតិថិជន

### អ្នកម៉ៅការវាយតម្លៃថាមពលក្នុងផ្ទះ

- ចាប់ផ្ដើមនៅក្នុងផែនការ 2022-2024, HPCs ត្រូវបានអនុញ្ញាតឱ្យបម្រើ អតិថិជន IE នៅក្នុងអគារ 1-4 យូនីត
  - ឥឡូវនេះ HPCs ផ្ដល់ប្រហែល 50% នៃផលិតកម្ម IE
- អ្នកជំនាញលក់ IE គ្រប់គ្រងការងារដែលជំរុញដោយ HPC។
- HPCs មិនធ្វើការងារណាមួយដែលពាក់ព័ន្ធនឹងការផ្ដល់មូលនិធិ WAP ឬ LIHEAP របស់សហព័ន្ធទេ
- HPCs អាចពិនិត្យប្រាក់ចំណូលរបស់អតិថិជន

# ដំណើររបស់អតិថិជនដែលមានសិទ្ធិទទួលបានប្រាក់ជំណាល

សេវាកម្មផ្តល់ជូនដោយ CAP

## ដំណើររបស់អតិថិជន

បទពិសោធអតិថិជនជម្មតាចាប់ពីទទួលចុះឈ្មោះរហូតដល់ដំឡើង



# សិទ្ធិទទួលបានប្រាក់ចំណូល

# គំរូគ្រប់គ្រងគម្រោង

## ការគាំទ្រពីអតិថិជន = ការគស្ម័មតិរបស់អតិថិជន

**ការចុះកិច្ចសន្យាទូទៅក្នុងនាមអតិថិជន**

| ការផ្សព្វផ្សាយ និងការទទួលចុះឈ្មោះ | ការវាយតម្លៃអគារ | ការជ្រើសរើសអ្នកម៉ៅការ | ការកំណត់ពេលវេលា និងការណែនាំរបស់អ្នកម៉ៅការដំបូង | ការគ្រប់គ្រងគុណភាព |
|---|---|---|---|---|
| ភ្នាក់ងារធ្វើការផ្សព្វផ្សាយ និងការទទួលចុះឈ្មោះតាមរយៈ LIHEAP និងប្រភពផ្សេងទៀត**ទីផ្សារដល់អតិថិជនបញ្ចុះតម្លៃទាំងអស់**ទាញយកអត្ថប្រយោជន៍ពីមូលនិធិមិនមែន PA។ | សវនករថាមពលដែលមានវិញ្ញាបនបត្រ BPI និងមានលក្ខណៈសម្បត្តិ DHCD វាយតម្លៃគម្រោងទាំងអស់ និងបង្កើតវិសាលភាពការងារ | ទីភ្នាក់ងារពិនិត្យអ្នកម៉ៅការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ និងអ៊ីសូឡង់ការពារកម្ដៅជាងដំបូល និងជាងអគ្គិសនីដែលមានអាជ្ញាបណ្ណ និងធានារ៉ាប់រងទាំងអស់ | សវនករថាមពលគ្រប់គ្រងគម្រោងទាំងអស់នៅក្នុងវិស័យនេះ – ការណែនាំអ្នកលក់ដំឡើងថ្ងៃដំបូង និងការត្រួតពិនិត្យ និងដោះស្រាយបញ្ហាក្នុងដំណើរការ | សវនករថាមពលធ្វើការត្រួតពិនិត្យគុណភាពចុងក្រោយ 100% ដើម្បីធានាបាននូវភាពពេញលេញ និងគុណភាពការងារ |

<u>គំរូអនុវត្ត “Quarterback” ធានានូវការងារប្រកបដោយប្រសិទ្ធភាពទូលំទូលាយក្នុងគុណភាពខ្ពស់ និងជាមួយនឹងការសន្សំដែលអាចវាស់វែងបាន និងអាចផ្ទៀងផ្ទាត់បានដោយមិនគិតថ្លៃដល់គ្រួសារ LI។</u>

# សិទ្ធិទទួលបានប្រាក់ជំនួយ

## មជ្ឈមណ្ឌលសេវាកម្មអតិថិជនទូទាំងរដ្ឋ (SCSC)

- គាំទ្រដោយ Eversource, National Grid, Berkshire Gas និង Unitil។
- ផ្ទះនៅ ABCD មានបុគ្គលិកចំនួន 10 នាក់
- ចន្លោះពីអតិថិជនសក្តានុពល 1,200-1,400 នាក់ក្នុងមួយខែពី CFP, HPCs, សាលាក្រុង, MR, ភ្នាក់ងាររដ្ឋ និង PAs
- ច្រើនភាសា
- ការត្រួតពិនិត្យការមានសិទ្ធិទទួលបាន និងប្រវត្តិសេវាកម្មប្រើប្រាស់កន្លងមក
- បន្ទាប់មក អតិថិជនសក្តានុពលត្រូវបានចែកចាយទៅ CAPs និង HPCs

**ការគាំទ្រភាសាផ្ទាល់របស់ SCSC៖**

- អារ៉ាប់
- អង់គ្លេស
- បារាំង
- កាប់វែរក្រេអូល
- ហៃទីក្រេអូល
- ព័រទុយហ្គាល់
- អេស្ប៉ាញ
- វៀតណាម

**ការគាំទ្រភាសាដោយបុគ្គលិករបស់ ABCD៖**

- ចិនកាតាំង
- ចិនកុកងឺ

# វិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម

សិទ្ធិទទួលបាន៖ អតិថិជនអាជីវកម្មដែលបង់គិតតាមកុងទ័រ

វិធីសាស្ត្រនៃកម្មវិធី៖

1. អគារថ្មី និងការជួសជុលកែកុនសំខាន់ៗ
2. អគារដែលមានស្រាប់
3. ការបង្វិលសងលើបរិក្ខារ និងការលើកទឹកចិត្តភ្លាមៗ
4. សេវាកម្មជាកញ្ចប់/ការកែកុនសម្រាប់អាជីវកម្មខ្នាតតូច

# ពាណិជ្ជកម្ម និងឧស្សាហកម្ម

## បណ្ដាញចែកចាយ

### សេវាកម្មជាកញ្ចប់សម្រាប់អាជីវកម្មខ្នាតតូច

- អ្នកលក់ជាប់កិច្ចសន្យាអនុវត្តការវាយតម្លៃថាមពលគ្រប់ជ្រុងជ្រោយដោយមិនគិតថ្លៃ បង្កើតគម្រោងពន្យល់ពីការចំណាយ និងដំឡើងនៅពេលអតិថិជនយល់ព្រម
- អ្នកម៉ៅការគ្រប់គ្រងការរាយការណ៍ទិន្នន័យទាំងអស់ទៅ PAs
- អ្នកម៉ៅការផ្ដល់សេវាធានា

### ការបង្វិលសងដែលបានកំណត់ជាមុន

- ផ្ដល់ការបង្វិលសងក្នុងមួយគោនសម្រាប់ម៉ូទ័របូមកម្ដៅ ការគ្រប់គ្រងប្រព័ន្ធភ្លើងបំភ្លឺ ឧបករណ៍កាត់ស្នៅជាដើម។ល។
- ត្រូវតែប្រើអ្នកម៉ៅការដែលមានអាជ្ញាបណ្ណសម្រាប់ការដំឡើង
- អតិថិជនដាក់សំណើសុំការបង្វិលសងទៅអ្នកលក់

### ការបង្វិលសងធម្មតា

- ផ្ដល់ជូននៅពេលដែលលក្ខណៈពិសេសរបស់អតិថិជន ទីតាំង ឬដំណើរការទាមទារឱ្យមានការវិភាគជាក់លាក់លើគម្រោងនៃការសន្សំថាមពល និងការចំណាយដែលបានដំឡើង
- ចូលរួមតាមរយៈអ្នកលក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ការសាកសួរអតិថិជនដោយផ្ទាល់ ឬការផ្សព្វផ្សាយពីអ្នកជំនាញសេវាអតិថិជន

### អ្នកជំនាញសេវាអតិថិជន

- ផ្ដល់សេវាកម្មគ្រប់គ្រងសម្រាប់អតិថិជន C&I ខ្នាតមធ្យម និងធំ

# ដំណើររបស់អតិថិជនអាជីវកម្មខ្នាតតូច C&I

ការចូលរួមរបស់អាជីវកម្មខ្នាតតូចក្នុងគម្រោង Mass Saves

សូមទាក់ទងម្ចាស់ឧបត្ថម្ភគម្រោង Mass Save របស់អ្នកដើម្បីកំណត់កាលវិភាគនៃការវាយតម្លៃថាមពលដោយមិនគិតថ្លៃ

អ្នកឯកទេសថាមពលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងធ្វើការវាយតម្លៃអគាររបស់អ្នក ដោយផ្ទាល់ ឬតាមអនឡាញ ដោយកំណត់វិធានការសន្សំសំចៃថាមពលដែលមានសក្តានុពល

- ការកែលម្អប្រព័ន្ធភ្លើងបំភ្លឺ ការកែលម្អប្រព័ន្ធ HVAC ការបំពាក់អ៊ីសូឡង់បំពង់ក្បាលរ៉ូប៊ីណេសន្សំសំចៃទឹក និងច្រើនទៀត

អាជីវកម្មរបស់អ្នកនឹងទទួលបានសំណើសន្សំថាមពលតាមតម្រូវការដែលរៀបរាប់លម្អិតអំពីការណែនាំអំពីការការសន្សំសំចៃថាមពល

វិធានការសន្សំសំចៃថាមពលដែលបានណែនាំនឹងត្រូវបានដំឡើងដោយអ្នកលក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់យើង ហើយបង់ប្រាក់រហូតដល់ 70 ភាគរយដោយម្ចាស់ឧបត្ថម្ភរបស់អ្នក

# មុខងារថ្មីមួយចំនួនសម្រាប់ឆ្នាំ 2025-2027

# មុខងារសំខាន់៖ សមធម៌

ការចែកចាយដោយយុត្តិធម៌គឺជាធាតុសំខាន់នៃការរៀបចំ និងការអនុវត្តកម្មវិធី

ការវិនិយោគលើសមធម៌ដែលមិនអាចប្រៀបផ្ទឹមបាន៖ $1.78 ប៊ីលានដុល្លារ
ការលើកទឹកចិត្តអ្នកជួល៖ $590 លានដុល្លារតាមរយៈការបង្កើនការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ និងម៉ូទ័របូមកម្ដៅនៅក្នុងសហគមន៍សមធម៌ដែលបានកំណត់

ការកែលម្អកម្មវិធីដើម្បីបង្កើនសេវាកម្មដល់អតិថិជនដែលមានប្រាក់ចំណូលមធ្យម អ្នកជួល និងអាជីវកម្មខ្នាតតូច៖

អចលនទ្រព្យជួល (អ្នកជួល 50%) នៅក្នុងសហគមន៍សមធម៌ដែលបានកំណត់មានសិទ្ធិទទួលបានដោយស្វ័យប្រវត្តិសម្រាប់ការលើកទឹកចិត្ត 100% សម្រាប់ការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ ម៉ូទ័របូមកម្ដៅនិងការ

ម៉ូទ័របូមកម្ដៅសម្រាប់អ្នកមានប្រាក់ចំណូលកម្រិតទាបនិងមធ្យមបានកើនឡើងពី 16,000 ទៅជិត 22,000 គ្រួសារ



# មុខងារសំខាន់៖ សហគមន៍សមធម៌ដែលបានកំណត់

- ការវិនិយោគបន្ថែមនៅក្នុងសហគមន៍ 21 កន្លែង "សហគមន៍សមធម៌ដែលបានកំណត់" (DECs) ដែលមានសមាមាត្រខ្ពស់នៃអចលនទ្រព្យជួល និងអតិថិជន LMI

- ត្រូវបានជ្រើសរើសជាមួយនឹងធាតុចូលសំខាន់ពី EWG

- អចលនទ្រព្យជួលមានសិទ្ធិទទួលបានការលើកទឹកចិត្ត 100% ដោយស្វ័យប្រវត្តិសម្រាប់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ ម៉ាស៊ីនបូមកម្ដៅ និងការកាត់បន្ថយឧបសគ្គតាមរយៈគំរូវិធីសាស្ត្រជាកញ្ចប់

- អចលនទ្រព្យ 1-4 ទាំងអស់មានសិទ្ធិទទួលទទួលបានដោយស្វ័យប្រវត្តិសម្រាប់ការលើកទឹកចិត្ត 100% សម្រាប់ការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ

- DECs ភាគច្រើនរួមបញ្ចូលកម្មវិធី Community First Partnership



# សហគមន៍សមធម៌ដែលបានកំណត់សម្រាប់ឆ្នាំ 2025-2027

## លក្ខណៈវិនិច្ឆ័យ៖ ភាគរយខ្ពស់នៃ LMI និងអ្នកជួល

- Boston (លេខកូដតំបន់ជាក់លាក់)
- Brockton
- Chelsea
- Everett
- Fall River
- Framingham
- Fitchburg
- Lawrence
- Lowell
- Lynn
- Malden
- New Bedford
- Oak Bluffs
- Pittsfield
- Quincy
- Revere
- Salem
- Springfield
- Tisbury
- Woburn
- Worcester

# មុខងារសំខាន់៖ កម្មវិធី Community First Partners

**សង្ខេបចំណុចសំខាន់ៗប្រចាំឆ្នាំ 2022 – 2024៖**

- សហគមន៍ចំនួន 52 កន្លែងទទួលបានអត្ថប្រយោជន៍ពីការផ្សព្វផ្សាយដែលដឹកនាំដោយសហគមន៍មូលដ្ឋាន
- 26 CFPs បានគាំទ្រសហគមន៍ដើម្បីជួយសម្រេចបាន៖
  - ការវាយតម្លៃថាមពលក្នុងផ្ទះចំនួន 98,103 ករណី
  - ការកែលម្អការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុចំនួន 23,932 ខ្នង
  - ការកែលម្អប្រព័ន្ធម៉ាស៊ីនកម្តៅ និងម៉ាស៊ីនត្រជាក់ក្នុងផ្ទះចំនួន 29,388 ខ្នង
  - ការកែលម្អការសន្សំសំចៃថាមពលអាជីវកម្មខ្នាតតូចចំនួន 2,709 កន្លែង (ដល់ឆ្នាំ 2023)
- CFPs ទទួលបានរហូតដល់ $60,000 ជាការផ្តល់មូលនិធិប្រចាំឆ្នាំ និងការគាំទ្រផ្នែកទីផ្សារ និងបច្ចេកទេស

**សម្រាប់ឆ្នាំ 2025-2027៖**

- **បង្កើនមូលនិធិ (រហូតដល់ $80,000)**
- **កែលម្អលទ្ធភាពចូលប្រើទិន្នន័យ**
- **ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ CFP ដើម្បីជំរុញការវាយតម្លៃអាជីវកម្មខ្នាតតូចបន្ថែមទៀត**
- **សមត្ថភាពក្នុងការរៀបចំសម្ភារៈធ្វើទីផ្សារ ការគាំទ្រពហុភាសាតាមតម្រូវការ**
- **58 CFPs បម្រើសហគមន៍ជាង 60 កន្លែង**



# កម្មវិធី Community First Partnerships ប្រចាំឆ្នាំ 2025-2027

Acton
Amesbury
Andover
Arlington
Attleboro
Aquinnah
Beverly
Boston (ទីក្រុង និងអង្គការ Boston Climate Action Network)
Brockton
Brookline
Cambridge
Chelmsford
Chelsea
Chilmark
Easthampton
Edgartown
Everett
Fall River

Framingham
Gloucester
Lawrence
Leominster
Lexington
Lowell
Lynn
Malden
Medford
Melrose
Methuen
Nantucket
Natick
New Bedford
Newburyport
Newton
Northampton

Norwood
Oak Bluffs
Pittsfield
Plymouth
Quincy
Randolph
Revere
Salem
Sharon
Sommerville
Southbridge
Springfield
Swampscott
Taunton
Tisbury
Watertown
W. Tisbury

Westborough
Westhampton
Winthrop
Woburn
Worcester

# លទ្ធភាពចូលប្រើភាសា

- PAs បានចូលរួមជាមួយអ្នកជំនាញលទ្ធភាពចូលប្រើភាសាភាគីទីបីដើម្បីបង្កើតអនុសាសន៍សម្រាប់ការកែលម្អលទ្ធភាពចូលប្រើភាសានៅទូទាំងកម្មវិធី
    - PAs បានអនុម័ត 20 អនុសាសន៍ក្នុងចំណោម 21 អនុសាសន៍
    - អនុសាសន៍ជាច្រើនត្រូវបានបញ្ចប់ ឬកំពុងដំណើរការ
- PAs បានវាយតម្លៃសមត្ថភាពភាសារបស់អ្នកម៉ៅការ និងបញ្ជីអ្នកម៉ៅការដែលបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីសមត្ថភាពភាសា
- PAs កំពុងតាមដានការចង់បានភាសានៅពេលទទួលចុះឈ្មោះអតិថិជននៅក្នុងកម្មវិធីដំណោះស្រាយជាកញ្ចប់សម្រាប់លំនៅឋាន
- ការបកប្រែគេហទំព័រជាភាសាអេស្ប៉ាញ និងព័រទុយហ្គាល់គឺធ្វើឡើងបន្តផ្ទាល់ ដោយធ្វើការបកស្រាយភាសាផ្សេងទៀតតាមក្រោយ
- កម្មវិធី Community First Partners' មានគេហទំព័រជាភាសាផ្សេងៗ រួមទាំងភាសាខ្មែរ និងភាសាកាប់វែរក្រេអូល
- គំនិតផ្តួចផ្តើមសំខាន់ៗនាពេលខាងមុខ៖
    - មជ្ឈមណ្ឌល Mass Save Statewide Solutions Center (បើកដំណើរការឆាប់ៗនេះ) និងអាចបម្រើអតិថិជនចំនួន 250 ភាសា
    - គាំទ្រការធ្វើបច្ចុប្បន្នភាពសុសវែរដែលទាក់ទងនឹងការបកប្រែសម្រាប់អ្នកលក់លំនៅឋាន
    - ការស្រាវជ្រាវ និងយុទ្ធនាការពហុវប្បធម៌ក្នុងចំណោមអ្នកនិយាយភាសាហៃទីក្រេអូល ចិនកុកងឺ និងចិនកាតាំង

# HEA ដែលមានប្រធានបទស្ដីពីការវិវឌ្ឍន៍ និងការកាត់បន្ថយកាបូន




- នៅតែជាការវាយតម្លៃដោយមិនគិតថ្លៃនៃការប្រើប្រាស់ថាមពលនៅក្នុងផ្ទះ ដែលកំណត់ឱកាសប្រសិទ្ធភាពថាមពល និងការកាត់បន្ថយកាបូនដែលពាក់ព័ន្ធ
- ឥឡូវនេះ រួមបញ្ចូលរបាយការណ៍ដែលបានរៀបចំតាមបំណង អនុសាសន៍ពាក់ព័ន្ធ និងការផ្ដល់ជូនរង្វាន់លើកទឹកចិត្ត ព្រមទាំងជំហានបន្ទាប់ច្បាស់លាស់ចំពោះដំណោះស្រាយកាត់បន្ថយកាបូនយ៉ាងទូលំទូលាយ

# របាយការណ៍ HEA ដែលត្រូវបានកែលម្អថ្មី

## មុខងារថ្មី/ប្រសើរឡើង

- រូបភាពបន្ថែម
- ខ្លឹមសារអប់រំសម្បូរបែប
- មុខងារពិសេសសម្រាប់អ្នកជួល និងអ្នកមានប្រាក់ចំណូលមធ្យម
- តំណភ្ជាប់បន្ថែមទៅកាន់ធនធានបន្ថែម
- ផែនទីបង្ហាញផ្លូវនៃការកាត់បន្ថយកាបូន
- ពេលវេលាដែលរំពឹងទុកផ្លាស់ប្តូរថ្មី

## ផែនទីបង្ហាញផ្លូវកាត់បន្ថយកាបូនរបស់អ្នក

### 1 ការកែលម្អការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ

ការបំពាក់អ៊ីសូឡង់ និងបិទរន្ធខ្យល់ក្នុងផ្ទះរបស់អ្នកគឺជាជំហានដំបូងដ៏សំខាន់មួយដើម្បីបង្កើនផាសុកភាព និងកាត់បន្ថយចំណាយលើម៉ាស៊ីនកម្តៅ និងម៉ាស៊ីនត្រជាក់។

ធ្វើការជាមួយអ្នកជំនាញថាមពលរបស់អ្នក
ដើម្បី៖

- ដោះស្រាយសកម្មភាពណាមួយដែលតម្រូវដោយអតិថិជន
- ចុះហត្ថលេខាលើកិច្ចសន្យាបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ
- កំណត់ពេលដំឡើង

### 2 ការផ្តល់កម្តៅនិងភាពត្រជាក់

បង្កើនផាសុកភាពរបស់អ្នកនៅផ្ទះដោយដំឡើងទៅប្រើម៉ូទ័របូមកម្តៅថ្មីដែលសន្សំសំចៃថាមពល។

របៀបចាប់ផ្តើម

- កំណត់ពេលពិគ្រោះយោបល់អំពីការកាត់បន្ថយកាបូនដោយមិនគិតថ្លៃ
- ប្រើប្រាស់ម៉ាស៊ីនគិតលេខប្រៀបធៀបប្រព័ន្ធម៉ាស៊ីនកម្តៅរបស់យើង

### 3 ឧបករណ៍

បង្កើនការអនុវត្តវិធានការដែលមានផលប៉ះពាល់ខ្ពស់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

- ម៉ាស៊ីនទឹកក្តៅប្រើម៉ូទ័របូមកម្តៅ
- ម៉ាស៊ីនសម្ងួតសម្លៀកបំពាក់ប្រើម៉ូទ័របូមកម្តៅ
- ចង្ក្រានអាំងឌុចស្យុង
- ឧបករណ៍កាត់ស្មៅ

នៅពេលអ្នកប្តូរឧបករណ៍ផ្សេងទៀត សូមពិចារណាវិញ្ញាបនបត្រ ENERGY STAR®

### 4 ថាមពលកកើតឡើងវិញ និងការដឹកជញ្ជូន

គិតអំពីការកាត់បន្ថយកាបូន និងប្រសិទ្ធភាពថាមពលជាមួយនឹងការទិញថ្មីសំខាន់ៗ ឬការកែលម្អផ្ទះ

- បន្ទះសូឡា PV
- ការស្តុកទុកអាគុយ
- រថយន្តអគ្គិសនី
- ឆ្នាំងសាករថយន្តអគ្គិសនី

## ពេលវេលាដែលរំពឹងទុកផ្លាស់ប្តូរថ្មី

នៅពេលអ្នកកំពុងព្យាយាមកាត់បន្ថយកាបូន ការតាំងឧបករណ៍ដែលមិននឹកស្មានដល់អាចធ្វើឱ្យមានភាពស្មុគស្មាញក្នុងការស្វែងរកដំណោះស្រាយផ្លាស់ប្តូរថ្មីដែលសមស្របក្នុងរយៈពេលខ្លី។ វិធីសាស្ត្រដ៏ល្អបំផុតគឺត្រូវរៀបចំផែនការជាមុន និងផ្លាស់ប្តូរឧបករណ៍មុនពេលវាខូច។ ពេលកំណត់ខាងក្រោមគូសបញ្ជាក់ពីកាលវិភាគផ្លាស់ប្តូរថ្មីដែលរំពឹងទុកសម្រាប់បរិក្ខារ ឧបករណ៍ និងរថយន្តបច្ចុប្បន្នរបស់អ្នក។ សូមចងចាំថាអ្នកអាចជ្រើសរើសប្តូររបស់របរទាំងនេះមុនពេលផុតកំណត់ដែលរំពឹងទុក។

**2025**

**ការបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ៖** ការបំពាក់អ៊ីសូឡង់ និងបិទរន្ធខ្យល់នៅក្នុងផ្ទះរបស់អ្នកគឺជាជំហានដំបូងក្នុងដំណើរកាត់បន្ថយកាបូនរបស់អ្នក ស្វែងយល់បន្ថែមនៅគេហទំព័រ៖ MassSave.com/Weatherization

**ការផ្តល់កម្តៅ និងភាពត្រជាក់៖** ដំឡើងទៅឧបករណ៍កម្តៅ និងត្រជាក់ដែលមានប្រសិទ្ធភាព ដូចជាម៉ូទ័របូមកម្តៅ។ ស្វែងយល់បន្ថែមនៅ៖ MassSave.com/HeatPump

**2026**

**ម៉ាស៊ីនបោកគក់សម្លៀកបំពាក់៖** សន្សំសំចៃថាមពល និងថវិកានៅផ្ទះ ខណៈពេលដែលកាត់បន្ថយការបំភាយកាបូនរបស់អ្នកដោយជ្រើសរើសម៉ាស៊ីនបោកគក់សម្លៀកបំពាក់ដែលមានវិញ្ញាបនបត្រ ENERGY STAR។ ស្វែងយល់បន្ថែមនៅ៖ MassSave.com/Washer

**ម៉ាស៊ីនសម្ងួតសម្លៀកបំពាក់៖** ដំឡើងទៅទៅជាម៉ាស៊ីនសម្ងួតសម្លៀកបំពាក់ដែលមានវិញ្ញាបនបត្រ ENERGY STAR ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល និងកាត់បន្ថយការបញ្ចេញកាបូន។ ស្វែងយល់បន្ថែមនៅ៖ MassSave.com/ClothesDryer

**2027**

**ចង្ក្រានអាំងឌុចស្យុង៖** ការចម្អិនអាហារដោយប្រើកម្តៅអាំងឌុចស្យុងធ្វើឱ្យពេលវេលាញ៉ាំអាហារកាន់តែងាយស្រួលជាមួយនឹងការកម្តៅកាន់តែលឿនជាងមុន ការគ្រប់គ្រងដ៏ច្បាស់លាស់ និងការសម្អាតដោយងាយស្រួល។ ស្វែងយល់បន្ថែមនៅ៖ MassSave.com/Weatherization

# វិធីសាស្ត្រផ្តល់សេវាកម្មជាកញ្ចប់

- ការពង្រីកការដឹកជញ្ជូនដើម្បីគាំទ្រដល់អតិថិជនដែលមានប្រាក់ចំណូលមធ្យមទូទាំងរដ្ឋ និងអចលនទ្រព្យជួលនៅក្នុង
  សហគមន៍សមធម៌ដែលបានកំណត់។

- អតិថិជនធ្វើការជាមួយអ្នកលក់ដែលគួរឱ្យទុកចិត្តចាប់ពីការវាយតម្លៃរហូតដល់ការបញ្ចប់គម្រោង
  - ការសម្របសម្រួលគម្រោង/ការគ្រប់គ្រងគម្រោងពីដើមដល់ចប់
  - អ្នកម៉ៅការបន្តត្រូវបានចាត់តាំង និងគ្រប់គ្រងដោយអ្នកលក់ (ឬអាចត្រូវបានជ្រើសរើសដោយអតិថិជន) ការត្រួតពិនិត្យការគ្រប់គ្រងគុណភាពក្រោយការដំឡើង
- បើកចំហសម្រាប់អតិថិជនដែលមានប្រាក់ចំណូលមធ្យមទូទាំងរដ្ឋ និងអចលនទ្រព្យជួលចំនួន 1-4 កន្លែងក្នុង21 DECs



# មុខងារសំខាន់៖ ការអភិវឌ្ឍ និងភាពចម្រុះនៃកម្លាំងពលកម្ម

## ការប្តេជ្ញាចិត្តក្នុងការពង្រឹង និងធ្វើពិពិធកម្មកម្លាំងពលកម្ម

- ការបង្កើនមូលនិធិដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងកម្លាំងពលកម្មរបស់ Mass CEC
    - ការបង្កើនមូលនិធិរហូតដល់ 24 លានក្នុងមួយឆ្នាំ
- បន្តការបណ្តុះបណ្តាល និងការអភិវឌ្ឍបណ្តាញជាងដំឡើងម៉ូទ័របូមកម្តៅ
- គោលដៅមហិច្ឆតាក្នុងការចំណាយ 15% នៃតម្លៃកិច្ចសន្យាគម្រោង Mass Save ដោយផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ចម្រុះ





# មជ្ឈមណ្ឌល Mass Save Solutions Center

**មជ្ឈមណ្ឌល MSSC នឹងផ្តល់៖**

- **ការគាំទ្រច្រើនភាសាពេញលេញ**ដល់អតិថិជនអាជីវកម្មខ្នាតតូច និងអតិថិជនតាមលំនៅឋានទូទាំងរដ្ឋសម្រាប់ការផ្តល់ជូននូវវិធានការសន្សំសំចៃថាមពល និងការបំពាក់ប្រព័ន្ធអគ្គិសនីទាំងអស់
- **ការណែនាំសម្រាប់អតិថិជនតាមលំនៅឋាន និងអតិថិជនអាជីវកម្មខ្នាតតូច**នៅពេលចាប់ផ្តើមដំណើរការកាត់បន្ថយប្លូនដែលចង់បានព័ត៌មានអំពីកន្លែង និងរបៀបចាប់ផ្តើម និងប្រភេទនៃដំណោះស្រាយជាសក្តានុពលជាច្រើនដែលមានសម្រាប់លំនៅឋាន ឬអាជីវកម្មខ្នាតតូចរបស់ពួកគេ

**មជ្ឈមណ្ឌល MSSC នឹងមានផ្តល់ជូនបុគ្គលិកឯកទេសតាមកម្មវិធី៖**

- **មានចំណេះដឹងអំពីការផ្តល់ជូនទាំងអស់របស់គម្រោង Mass Save** ដែលអាចជួយណែនាំកម្មវិធី ការវាយតម្លៃថាមពលក្នុងផ្ទះ ប្រាក់កម្ចីសម្រាប់ប្រព័ន្ធម៉ាស៊ីនកម្តៅ ប្រាក់កម្ចីកម្មវិធី Climate Bank Energy Saver ការពិគ្រោះយោបល់អំពីការកាត់បន្ថយកាបូន ឥណទានពន្ធពាក់ព័ន្ធ ការលើកទឹកចិត្តរបស់សហព័ន្ធ និងស្ថានភាពនៃការបង្វិលសង
- **ទទួលបានការបណ្តុះបណ្តាល និងបំពាក់បំប៉នជំនាញដើម្បីជួយអតិថិជន** មានលទ្ធភាពទទួលបានការលើកទឹកចិត្តក្រៅពីគម្រោង Mass Save ដូចជាការលើកទឹកចិត្តសម្រាប់រថយន្តអគ្គិសនី និងការដំឡើងផ្ទាំងសូឡាចែកចាយថាមពល

**អតិថិជននឹងអាច៖**

- **មានលទ្ធភាពទទួលបានធនធានដ៏ទូលំទូលាយទាំងនេះតាមរយៈទូរសព្ទ កម្មវិធីជជែក និងអ៊ីមែល**

**ការដាក់ឲ្យប្រើប្រាស់៖ ត្រីមាសទី 4 ឆ្នាំ 2025**

# ទីផ្សារអនឡាញសម្រាប់ម៉ាស៊ីនទឹកក្ដៅប្រើម៉ូទ័របូមកម្ដៅ (HPWH)

- សំណួរមុនពេលពិនិត្យកំណត់ថាតើលក្ខណៈផ្ទះរបស់អតិថិជនសមរម្យសម្រាប់ការដំឡើង និងការប្រើប្រាស់ HPWH ឬអត់
- ខ្លឹមសារអប់រំពហុភាសា
- ការបង្វិលសងភ្លាមៗ
- ជម្រើសសម្រាប់ការដឹកជញ្ជូនផលិតផល ការទៅយក ឬការដំឡើងដោយជាងជំនាញ
- ម៉ាស៊ីនគិតលេខប្រៀបធៀបប្រព័ន្ធកម្ដៅទឹកអនុញ្ញាតឱ្យអតិថិជនប្រៀបធៀបថ្លៃចំណាយប្រតិបត្តិការ HPWH ទល់នឹងជម្រើសកម្ដៅទឹក និងប្រភេទឥន្ធនៈផ្សេងទៀត

- [ការបង្វិលសងលើម៉ាស៊ីនទឹកក្ដៅប្រើម៉ូទ័របូមកម្ដៅ | លំនៅឋាន | គម្រោង Mass Save]




ដល់ពេលត្រូវប្ដូរទៅម៉ាស៊ីនទឹកក្ដៅប្រើម៉ូទ័របូមកម្ដៅដែលមានការបញ្ចុះតម្លៃភ្លាមៗពីម្ចាស់ឧបត្ថម្ភគម្រោង Mass Save ហើយ។

សន្សំសំចៃលើវិក្កយបត្រថាមពលរបស់អ្នក ខណៈពេលដែលបំពេញតម្រូវការទឹកក្ដៅរបស់ផ្ទះរបស់អ្នកបានយ៉ាងងាយស្រួល នៅពេលអ្នកដំឡើងសេរីពីម៉ាស៊ីនទឹកក្ដៅអគ្គិសនីចាស់របស់អ្នកទៅម៉ាស៊ីនទឹកក្ដៅប្រើម៉ូទ័របូមកម្ដៅ ដែលមានវិញ្ញាបនបត្រ ENERGY STAR® តាមរយៈទីផ្សារម៉ាស៊ីនទឹកក្ដៅប្រើម៉ូទ័របូមកម្ដៅរបស់គម្រោង Mass Save។

# ការពិគ្រោះយោបល់អំពីការកាត់បន្ថយកាបូន

- សរុបបានបញ្ចប់ចាប់តាំងពីខែកុម្ភៈ ឆ្នាំ 2024៖ **2,930**
- ការប្រៀបធៀបសម្រង់តម្លៃបានចាប់ផ្ដើមដំណើរការជាបណ្ដោះអាសន្ននៅក្នុងខែសីហា ឆ្នាំ 2024 ជាមួយនឹងការប្រៀបធៀបសម្រង់តម្លៃចំនួន **167** ករណីដែលបានបញ្ចប់រហូតមកដល់បច្ចុប្បន្ន
- មានបុគ្គលិកជំនាញដែលចេះនិយាយភាសា *អេស្ប៉ាញ* និងព័រទុយហ្កាល់
- អ្នកលក់បានសហការជាមួយសេវាកម្មបកប្រែដើម្បីគាំទ្រអតិថិជនដែលនិយាយ*ភាសាចិនកុកងឺ ចិនកន្តាំង ខ្មែរ និងហៃទីក្រេអូល*
- ការកំណត់ពេលវេលាតាមអនឡាញ និងឯកសារពិគ្រោះយោបល់ដែលបានបកប្រែ រួមទាំងការស្ទង់មតិមុនពិគ្រោះយោបល់ និងរបាយការណ៍ក្រោយពិគ្រោះយោបល់ដែលមាននៅក្នុង LOTE ចំនួនប្រាំ
- រហូតមកដល់បច្ចុប្បន្ន ហេតុផលចម្បងដែលអតិថិជនកំណត់ពេលវេលាពិគ្រោះយោបល់គឺដើម្បី "ស្វែងយល់ពីបច្ចេកវិទ្យា" ជាពិសេសម៉ូទ័របូមកម្ដៅជាមួយអ្នកជំនាញបច្ចេកទេស






# ឧបសម្ព័ន្ធ

# វឌ្ឍនភាពដែលសម្រេចបានចាប់តាំងពីឆ្នាំ 2023

បានបំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុប្រ 530,000 **350,00 ខ្នង** រួមទាំង **គ្រួសារដែលមានប្រាក់ចំណូល ទាបចំនួន 70,000 គ្រួសារ។**

បានគាំទ្រការដំឡើងម៉ូទ័របូមកម្ដៅ **នៅក្នុងផ្ទះ និងអាជីវកម្មសរុប** 105,000 **000 កន្លែង** (ចាប់តាំងពីឆ្នាំ 2019) រួមទាំង **គ្រួសារដែលមាន ប្រាក់ចំណូលទាបចំនួន 3,600 គ្រួសារ។**

13,000

បានកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) ចំនួន **3.7** 7.8 **នម៉ែត្រតោន** នៃសមមូលកាបូនឌីអុកស៊ីត ($CO_2e$) ដូចគ្នានឹងការដករថយន្តចំនួន 800,000 គ្រឿងចេញពីផ្លូវរយៈពេល

850,000

បានផ្ដត់ផ្គង់ថាមព 157 ាង **153 លានមេហ្គាវ៉ាត់ម៉ោង (MWh)** និង **4.7 ប៊ីលានទែ** 5.1 ការសន្សំសំចៃថាមពល ក៏ដូចជា **$31 លានដុល្លារ** នៃអត្ថប្រយោជន៍សរុបដល់អតិថិជន។ $34

បានវិនិយោ $1.3 ប្រាក់ **$1.1 ប៊ីលានដុល្លារ លើការកែលម្អ** ដែលកាត់បន្ថយចំណាយថាមពល និងកែលម្អសុខភាព សុវត្ថិភាព និងផាសុកភាពសម្រាប់គ្រួសារដែលមានចំណូលទាប។

បានផ្ដល់រង្ $7.8 វ័កទឹកចិត្តចំនួន **6.7 ប៊ីលានដុល្លារ** ដល់អតិថិជន។

# បីឆ្នាំបន្ទាប់

បំពាក់ប្រព័ន្ធការពារផ្ទះពីអាកាសធាតុ **163,000** ខ្នង រួមទាំងគ្រួសារដែលមានប្រាក់ចំណូលទាប និងមធ្យមចំនួន **69,000** គ្រួសារ និងផ្ទះជួលចំនួនជាង **49,000** ខ្នង។

ផ្តល់ថាមពល **8.2 លាន MWh** និង **1 ប៊ីលានទែម្ម** ក្នុងការសន្សំសំចៃថាមពល និងអត្ថប្រយោជន៍សរុបចំនួន **$12.1 ប៊ីលានដុល្លារ** ដុល្លារដល់អតិថិជន។

គាំទ្រដល់ការដំឡើងម៉ូទ័របូមកម្តៅនៅក្នុងគ្រួសារជាង **87,000** គ្រួសារ រួមទាំងគ្រួសារដែលមានប្រាក់ចំណូលទាប និងមធ្យមចំនួន **21,800** គ្រួសារ និងផ្ទះជួលជាង **13,000** ខ្នង។

**ការវិនិយោគទាក់ទងនឹងសមធម៌ជាង $1.78 ប៊ីលានដុល្លារ** រួមទាំង **រង្វាន់លើកទឹកចិត្តចំនួន $1.2 ប៊ីលានដុល្លារ**ដែលបានបង់ទៅឱ្យអតិថិជនដែលមានប្រាក់ចំណូលទាប និងមធ្យម និងជាង **$592 លានដុល្លារ**សម្រាប់អ្នកជួល។

កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ **864,000 ម៉ែត្រតោន នៃ CO2e**។

បានផ្តល់រង្វាន់លើកទឹកចិត្តចំនួន **$3 ប៊ីលានដុល្លារ**ដល់អតិថិជន។

# មុខងារសំខាន់៖ ការលើកទឹកចិត្តសម្រាប់ការអនុវត្ត

## សំណើលើកទឹកចិត្តសម្រាប់ការអនុវត្តឆ្នាំ 2025-2027

| សមាសភាគ | អ្វីដែលដាក់បញ្ចូល | % នៃចំនួនសរុប PI Pool | កម្រិតកំណត់ | កំណត់លើសពី 100% នៃការរៀបចំ PI (កម្រិត 125%) |
|---|---|---|---|---|
| **សមធម៌** | សេវាកម្មជាកញ្ចប់សម្រាប់អ្នកមានប្រាក់ចំណូលទាប (មិនមានសកម្មភាពឥន្ធនៈហ្វូស៊ីល) អ្នកមានប្រាក់ចំណូលមធ្យម អ្នកជួល និងអាជីវកម្មខ្នាតតូចទូទាំងរដ្ឋ | 50% | 65% | • ម៉ូទ័របូមកម្តៅ LMI<br>• អត្ថប្រយោជន៍អ្នកជួល |
| **ស្តង់ដារ** | ផលិតកម្មមិនមានសមធម៌ទាំងអស់ | 30% | *60%* | • សរុបអត្ថប្រយោជន៍ C&I (មិនមែនសេវាកម្មជាកញ្ចប់)<br>• អត្ថប្រយោជន៍សេវាកម្មជាកញ្ចប់ C&I |
| **គុណតម្លៃ** | អត្ថប្រយោជន៍សរុបដកថ្លៃកម្មវិធី ដោយមិនរាប់បញ្ចូលការចំណាយដែលមិនអាចគ្រប់គ្រងបាន ដូចជាការផ្តល់មូលនិធិ MassCEC ជាដើម។ | 20% | 75% | • ការចំណាយសរុបមិនមែនការលើកទឹកចិត្ត (មិនរាប់បញ្ចូលការវាយតម្លៃ) / អត្ថប្រយោជន៍សរុប |

- សរុប PI Pool កំណត់នៅ $190M, PAs កាត់បន្ថយ 10% មកត្រឹម $171M
- កម្រិតស្តង់ដារនៃសមាសភាគផ្អែកលើការប្រមូលផ្តុំអត្ថប្រយោជន៍ទាំងមូល ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃអត្ថប្រយោជន៍សមធម៌
- ការកំណត់រារាំងប្រាក់ចំណូលលើសពីកម្រិតរៀបចំ (100%) រហូតដល់គោលដៅដាក់លាក់បានបញ្ចប់

# សំណួរ និងមតិយោបល់សាធារណៈ

*សូមកំណត់មតិយោបល់នីមួយៗត្រឹមរយៈពេលពីរនាទី*
*ដើម្បីទុកពេលឱ្យអ្នកដទៃទៀតបញ្ចេញមតិ*




# ជំហានបន្ទាប់ និងការលើកវារកាល

ព័ត៌មានអំពី EJC និងកិច្ចប្រជុំនេះអាចត្រូវបានរកឃើញនៅលើគេហទំព័រ៖ https://www.mass.gov/orgs/environmental-justice-council-ejc